# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការកំណត់ផ្ទៃដីកោះពេជ្រ សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍កោះពេជ្រ ស្ថិតក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងលទ្ធផលនៃការសិក្សាបញ្ចប់លើលក្ខណៈបច្ចេកទេស នៃគម្រោងអភិវឌ្ឍន៍កោះពេជ្រ របស់គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានកំណត់ផ្ទៃដីកោះពេជ្រ សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍កោះពេជ្រ ស្ថិតក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ មានផ្ទៃសរុបចំនួន ៧៦,២៨ ហិកតា ( ចិតសិបប្រាំមួយក្បៀសម្ភៃប្រាំបី ហិកតា) តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ Geocraphical Position System, GPS DATUM : INDIAN - THAILAND 1960 ) រួមមាន ៣៤ ចំណុច ដូចខាងក្រោម :

| ល.រ | ចំណុច | អាប់ស៊ីស | អ័រដោនេ | ល.រ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|---|---|
| 1 | A | 494 000 | 1 277 200 | 18 | R | 493 400 | 1 275 685 |
| 2 | B | 494 100 | 1 277 155 | 19 | S | 493 300 | 1 275 760 |
| 3 | C | 494 200 | 1 277 100 | 20 | T | 493 280 | 1 275 855 |
| 4 | D | 494 280 | 1 277 000 | 21 | U | 493 300 | 1 275 945 |
| 5 | E | 494 310 | 1 276 900 | 22 | V | 493 360 | 1 276 100 |
| 6 | F | 494 330 | 1 276 800 | 23 | W | 493 435 | 1 276 200 |
| 7 | G | 494 335 | 1 276 700 | 24 | X | 493 525 | 1 276 300 |
| 8 | H | 494 325 | 1 276 600 | 25 | Y | 493 640 | 1 276 400 |
| 9 | I | 494 315 | 1 276 500 | 26 | Z | 493 735 | 1 276 500 |
| 10 | J | 494 285 | 1 276 400 | 27 | AA | 493 800 | 1 276 600 |
| 11 | K | 494 230 | 1 276 300 | 28 | AB | 493 845 | 1 276 700 |
| 12 | L | 494 160 | 1 276 200 | 29 | AC | 493 865 | 1 276 800 |
| 13 | M | 494 065 | 1 276 100 | 30 | AD | 493 870 | 1 276 900 |
| 14 | N | 493 945 | 1 276 000 | 31 | AE | 493 870 | 1 277 000 |
| 15 | O | 493 800 | 1 275 900 | 32 | AF | 493 870 | 1 277 100 |
| 16 | P | 493 600 | 1 275 795 | 33 | AG | 493 875 | 1 277 170 |
| 17 | Q | 493 500 | 1 275 740 | 34 | AH | 493 935 | 1 277 195 |

**មាត្រា ២ :** ផែនទីបង្ហាញទីតាំង សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍កោះពេជ្រ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣ :** បទដ្ឋានបច្ចេកទេសទាក់ទងនឹងរបបជលសាស្ត្រ ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍កោះពេជ្រត្រូវបានកំណត់ដូចខាងក្រោម :

១- **ទន្លេបាសាក់តូច :** ទន្លេបាសាក់តូច ត្រូវស្តារទទឹងមាត់លើពី ៩០ ម៉ែត្រ ទៅ ១០០ ម៉ែត្រ ទទឹងបាតក្រោមពី ៤០ ម៉ែត្រ ទៅ ៥០ ម៉ែត្រ និងក្រិតកំពស់បាតទន្លេ ក្រោយពីស្តារហើយ ស្មើនឹង-១,០០ ម៉ែត្រ (ធៀបនឹងកំពស់ទឹកសមុទ្រ) ពោលគឺ ទាបជាងកំពស់ទឹកនៅរដូវប្រាំង ១,៥០ ម៉ែត្រ និងមានជម្រាលជើងទេទន្លេ (m =1:5,00) ។ ក្នុងករណីអនុវត្តលក្ខខណ្ឌនេះមិនបាន ចាំបាច់ត្រូវធ្វើការរុះរើសំណង់ការពារច្រាំង ដែលបានធ្វើរួចកន្លងមក ។

២- **ទន្លេធសាក់ធំ :** ត្រូវស្តារដីនៅច្រាំងជាប់នឹងកោះពេជ្រ ដោយរក្សាជំរាលជើងទេទន្លេជាប់កោះពេជ្រ (៣ =1:7,00) នៅផ្នែកខាងលើក្រិតកំពស់ទឹកអប្បបរមា និង (៣ =1:10) នៅផ្នែកខាងក្រោមក្រិតកំពស់ទឹកអប្បបរមា ហើយនិងទទឹងមាត់លើពី ៤២០ ម៉ែត្រ ទៅ ៤៥០ ម៉ែត្រ នៅរដូវវស្សា ។

៣- **ច្រាំងទន្លេនៅប៉ែកខាងកោះនរា :** ចាំបាច់ត្រូវធ្វើការការពារច្រាំងដំណាលគ្នានឹងការអនុវត្តគម្រោងអភិវឌ្ឍន៍កោះពេជ្រ ។ ការធ្វើរបាំងការពារច្រាំងនេះ ត្រូវមានការសហការជាមួយស្ថាប័នជំនាញ ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ ✓

# ផែនទីកំណត់ទីតាំងអភិវឌ្ឍន៍កោះពេជ្រ

